ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៦៨
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១

សាលដីកា
លេខ: ៦៨៧
ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ០៤ ក្រVI "អ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៦៨ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូល។

ពិរុទ្ធ: ផ្តល់សក្ខីភាពក្លែងក្លាយ និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា៥០,៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ជនជាប់ចោទឈ្មោះ [redacted] (ម្ចាស់បណ្តឹងសារទុក្ខ) ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរពាណិជ្ជករ ទីកន្លែងកំណើតភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិអណ្តូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ទោសពីមុនគ្មាន។ ឃាត់ខ្លួនថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ ឃុំខ្លួនថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨។



Scanned by CamScanner

មានមេធាវីលោកស្រី [redacted]

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] (ចុងបណ្ដឹងសាទុក្ខ)-ភេទប្រុស អាយុ៥៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ២៤៥ ផ្លូវលេខ១០១៩ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

-កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៣ បានធ្វើសកម្មភាពជាមួយគូកនក្លែងលិខិតឯកជន និងផ្ដល់សក្ខីភាពក្លែងក្លាយក្នុងគោលបំណងបន្លំឈ្មោះស្នាមមេដៃរបស់ឈ្មោះ [redacted] ដើម្បីរំលោភយកដីនៅចំណុចភូមិប៉ាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ពីម្ចាស់កម្មសិទ្ធិខាងលើ។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថា:សម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ៣៨ឆ្នាំ ទៅជំនុំជម្រះ និងលើកលែងចោទប្រកាន់គូកន។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៨"ឆ" ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេច៖

១-ផ្ដន្ទាទោសឈ្មោ[redacted]ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអណ្ដូងផ្លូវលំ ឃុំគោករការ ស្រុកដង្កោ ខេត្តកណ្ដាល ទីលំនៅពេលចាប់ខ្លួនភូមិអណ្ដូង សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ មុខរបរពាណិជ្ជករ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោ[redacted]កូនគ្មាន ទោសពីមុនគ្មាន។

ដាក់ពន្ធនាគារសរុបកំណត់៤ឆ្នាំ (បួនឆ្នាំ) គិតបន្តពីសាលក្រមមុន និង ពិន័យជាប្រាក់ចំនួន៤.០០០.០០០៛០០ (បួនលានរៀល) សំរាប់ដាក់ចូលក្នុងថវិការដ្ឋ ពីបទ: ផ្ដល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៤, ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៣ និថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៥០, ៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-បង្គាប់អោយឈ្មោះ [redacted]សងថ្លៃខូចខាត និងជំងឺចិត្តគិតជាប្រាក់ចំនួន ៤០.០០០.០០០៛០០ (សែសិបលានរៀល) ឲ្យទៅដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ដែលមានលោកមេធាវី[redacted]ជាតំណាង។ សុំលើសពីនេះត្រូវច្រានចោល។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២៧៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៧ ទៅព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីបើកការស៊ើបសួរលើគូកន និងចាត់ការតាមនីតិវិធី។



Scanned by CamScanner

៤-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ ចំពោះមុខជនជាប់ចោទឈ្មោះ[redacted] មេធាវីការពារជនជាប់ចោទ មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៣០៥ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោះ[redacted]ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ៤៨"ឆ" ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពលើជនជាប់ចោទ[redacted]ពិបទ ផ្តល់សក្ខីភាពក្លែង និងក្លែងលិខិតឯកជនដូចបទចោទប្រកាន់របស់អយ្យការ។

សំអាងហេតុ និងសេចក្តីសំរេច នៃសាលក្រមលេខ៤៨ "ឆ" ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ សំរេចមកនេះឃើញថាត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០៤ "ក្រVIអ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៩ របស់ឈ្មោ[redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៤៨ "ឆ" ចុះថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០០៩ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការពេញទាំងមូល។

៣-បន្តការឃុំខ្លួនជនជាប់ចោទឈ្មោះ[redacted]តាមនីតិវិធីច្បាប់។

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ កំបាំងមុខមេធាវីការពារជនជាប់ចោទ និងជនជាប់ចោទ។

បើកសិទ្ធិឲ្យប្តឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៥៥ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់ជនជាប់ចោទឈ្មោះ[redacted]ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ០៤ "ក្រVIអ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍



Scanned by CamScanner

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា:

១-ទទួលបណ្តឹងសាទុក្ខដូចបញ្ជាក់ខាងលើ ដោយចាត់ទុកជាត្រឹមត្រូវតាមគតិច្បាប់។

២-បដិសេធចោលសាលដីការបស់សាលាឧទ្ធរណ៍ទុកជាមោឃៈពេញទាំងមូល។

៣-បង្វិលសំណុំរឿងនេះទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះឡើងវិញលើជនជាប់ចោទឈ្មោះ [redacted] បទ ក្លែងលិខិតឯកជន។

-បានស្តាប់សាវតាជាតិ និងចំលើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការថា៖ មូលហេតុអ្វីបានជាអ្នកឯងប្តឹងសាទុក្ខ? ខ្លួនប្តឹងសាទុក្ខដោយសារតែតុលាការផ្តន្ទាទោសខ្លួនច្រើនពេក ការក្លែងលិខិតនេះគឺខ្លួនបានទិញដីពីឈ្មោះ [redacted] ខ្លួនមិនដឹងពីការក្លែងទេ [redacted] នេះជាអ្នកកណ្តាលក្នុងការលក់ ចំណែកខ្លួនអ្នកទិញមិនបានទាក់ទងជាមួយអ្នកលក់ដីផ្ទាល់ទេ។ ឯកសារទាំងអស់ឈ្មោះ [redacted] ជាអ្នកធ្វើ ឯប្រាក់ខ្លួនជាអ្នកប្រគល់ឱ្យឈ្មោះ [redacted] ទាំងអស់ជាង១០ម៉ឺនដុល្លា ក្រោយពីទិញហើយឆ្នាំ១៩៩៣ ខ្លួនបានចូលកាន់កាប់ដីព្រមទាំងបានចិញ្ចឹមត្រី, ចិញ្ចឹមទា លុះដល់ឆ្នាំ២០០៧ ទើបម្ចាស់ដីគេប្តឹងយកដីគេវិញ ដោយចោទខ្លួនថា ផ្តល់សក្ខីភាពក្លែងក្លាយ និងក្លែងលិខិតយកដីចំនួន១១ហិកតា ដែលខ្លួនបានទិញពីឈ្មោះ [redacted] នោះ។ ដីទាំង១១ហិកតានោះក្រោយពីខ្លួនគ្រប់គ្រងហើយ ខ្លួនក៏បានដាក់ពាក្យបណ្តឹងទៅតុលាការក្រុងភ្នំពេញ ដើម្បីចេញសាលក្រមធ្វើប័ណ្ណកម្មសិទ្ធដាក់ឈ្មោះខ្លួន។ ដូច្នេះ ខ្លួនសុំបដិសេធបទផ្តល់សក្ខីភាពក្លែង ឯបទក្លែងលិខិតឯកជនខ្លួនសុខចិត្តទទួល។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ពុំមានយោបល់អ្វីបន្ថែមទៀតទេ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ៥៥ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់ឈ្មោះ [redacted] ស្ថិតនៅក្នុងកំណត់ច្បាប់ ដែលតុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី និងមាត្រា៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned by CamScanner

-យល់ឃើញថា ការដែលសាលាដំបូងរាជធានីភ្នំពេញក៏ដូចជាសាលាឧទ្ធរណ៍ផងដែរ ដែលសម្រេចផ្តន្ទាទោសឈ្មោះ [redacted] បទ: សក្ខីភាពក្លែងក្លាយនោះ គឺជាការភ័ន្តច្រឡំ ពីព្រោះថា មាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលចែងអំពីបទល្មើសសក្ខីភាពក្លែងក្លាយ គឺសំដៅអនុវត្តទៅលើប្រធាននៃបទល្មើស គឺជាសាក្សី និងអ្នកជំនាញដែលបានបង្ហាញភស្តុតាង ឬហេតុផលណាដែលមិនពិតដល់តុលាការ ប៉ុន្តែករណីនេះចំពោះជនជាប់ចោទឈ្ម[redacted]វិញ គឺជាភាគីនៅក្នុងរឿងក្តី។ ហេតុដូច្នេះ បញ្ញត្តិច្បាប់ខាងលើមិនអាចយកមកអនុវត្តធ្វើការចោទប្រកាន់លើឈ្មោ[redacted] បានទេ។ ដូចនេះតាមមាត្រា៤៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលសម្រេចឱ្យជនជាប់ចោទឈ្មោះ[redacted] រួចផុតពីបទល្មើសផ្តល់សក្ខីភាពក្លែងក្លាយ។ រីឯតុលាការអង្គសេចក្តី សម្រេចផ្តន្ទាទោសឈ្មោះ [redacted] ពីបទ ក្លែងលិខិតឯកជន នោះជាការត្រឹមត្រូវហើយ ប៉ុន្តែដោយនាពេលបច្ចុប្បន្ន ក្រមព្រហ្មទណ្ឌមានអានុភាពអនុវត្ត ហើយតាមបញ្ញត្តិមាត្រា៦២៧ នៃក្រមថ្មីនេះចែងអំពីទោសចំពោះបទល្មើសក្លែងបន្លំឯកសារមានលក្ខណៈស្រាលជាងទោស ដែលមានចែងក្នុងបញ្ញត្តិមាត្រា៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលជាច្បាប់ចាស់នោះ។ ដូច្នេះ តាមស្មារតីនៃមាត្រា១០ នៃក្រមព្រហ្មទណ្ឌ តុលាការគប្បីយកបទបញ្ញត្តិនៃច្បាប់ថ្មី ដែលចែងអំពីទោសស្រាលជាង មកអនុវត្តដើម្បីជាផលប្រយោជន៍របស់ជនជាប់ចោទ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ០៤ "ក្រVIអ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះខុសខ្លះត្រូវខ្លះ។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

១-ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ៥៥ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ របស់ឈ្មោះ [redacted]

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ០៥ "ក្រVIរ" ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែសេចក្តីសំរេចត្រង់ចំណុចទី២ ដែលត្រូវបដិសេធចោល។

៣-សម្រេចឱ្យឈ្មោះ[redacted] រួចផុតពីបទ ផ្តល់សក្ខីភាពក្លែង ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី០៤ ខែតុលា ឆ្នាំ២០០៤, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៣ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៣ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោស តាមមាត្រា៥៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ៦៨ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះលើការផ្តន្ទាទោសជនជាប់ចោទឈ្មោ[redacted] ពីបទក្លែងលិខិតឯកជន។



Scanned by CamScanner

៥-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ៥ ឆ្នាំ២០១៣

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]



Scanned by CamScanner